**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃពុធ ១១ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥*

*រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ
# ស្តីពីគោលនយោបាយ និង ទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

បច្ចេកវិទ្យាឌីជីថល ជាផ្នែកមួយដ៏សំខាន់នៃជីវិតរស់នៅប្រចាំថ្ងៃ និង ផ្តល់នូវកាលានុវត្តភាពសម្រាប់ការបង្កើតនូវធុរកិច្ចថ្មីៗដែលមានសក្តានុពល និង នវានុវត្តន៍។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការទាញយកឧត្តមប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថលក្នុងការកសាងសេដ្ឋកិច្ចឌីជីថលដែលនឹងក្លាយជាសសរស្តម្ភដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់ប្រទេសកម្ពុជា។ ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩, បច្ចេកវិទ្យាឌីជីថលបានចូលរួមចំណែកកាន់តែខ្លាំងក្នុងការរក្សាស្ថិរភាព និង សកម្មភាពសេដ្ឋកិច្ច, ការជំរុញពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើតឱកាសការងារក៏ដូចជាអាជីវកម្មថ្មីៗដែលមានសក្តានុពល។ ក្នុងន័យនេះ, ឌីជីថលូបនីយកម្មបានក្លាយជានិន្នាការ និង ជាកម្លាំងចលករដ៏មានឥទ្ធិពល ក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា។

កាលពីខែ ឧសភា ឆ្នាំ ២០២១, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ **"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** ដោយចាត់ទុកសេដ្ឋកិច្ចឌីជីថល ជាចន្ទល់កំណើនសេដ្ឋកិច្ចថ្មីផង និង ជាប្រព័ន្ធអេកូឡូស៊ីរួមចំណែកបង្កើនផលិតភាពសេដ្ឋកិច្ចនៅក្នុងវិស័យផ្សេងទៀត។ បច្ចេកវិទ្យាហិរញ្ញវត្ថុដែលជាទូទៅត្រូវបានគេហៅថា FinTech គឺជាមូលដ្ឋានដ៏ចាំបាច់មួយផងដែរ ក្នុងនិម្មាបនកម្មសេដ្ឋកិច្ចឌីជីថល។ យ៉ាងណាមិញ, វិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាបាននិងកំពុងប្រឈមមុខជាមួយបញ្ហាមួយចំនួន រួមមាន៖ កង្វះខាត និង ភាពមិនច្បាស់លាស់ក្នុងក្របខណ្ឌបទប្បញ្ញត្តិ, កង្វះខាតការគាំទ្រដល់ការអនុវត្តឌីជីថល, កង្វះខាតធនធានមនុស្ស និង កង្វះខាតនូវនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យដទៃទៀត ក្រៅពីវិស័យធនាគារ។

ដើម្បីកសាងវិធានគោលនយោបាយរួមក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា, **គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល នៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល** បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី **"គោលនយោបាយ និង ទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា"** រយៈពេលមួយថ្ងៃកន្លះ នាថ្ងៃទី ២៦ និង ២៧ ខែ មេសា ឆ្នាំ ២០២២ វេលាម៉ោង ៨:៣០ នាទី ព្រឹក នៅ សណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ (Hyatt Regency Phnom Penh)។ សិក្ខាសាលានេះត្រូវបានប្រារព្ធឡើង ក្រោមអធិបតីភាពដ៏

ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ហើយក៏មានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំក្រសួង, តំណាងក្រសួង-ស្ថាប័ន, ស្ថានទូត, ដៃគូអភិវឌ្ឍន៍, គ្រឹះស្ថានហិរញ្ញវត្ថុធនាគារ និងមិនមែនធនាគារ, សមាគម, ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ, ធុរជន និង នវានុវត្តជន។

សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី **"គោលនយោបាយ និង ទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា"** ត្រូវបានរៀបចំឡើងក្នុងគោលបំណងសំខាន់ៗចំនួន ៣ រួមមាន៖ (១) ប្រមូលធាតុចូលពីដៃគូពាក់ព័ន្ធសម្រាប់ការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា, (២) លើកកម្ពស់ការយល់ដឹងអំពីការវិវត្តវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន និង បញ្ហាប្រឈមក្នុងប្រទេសកម្ពុជា, និង (៣) ចែករំលែកគំនិត និង ទស្សនវិស័យរបស់អ្នកជំនាញ ដែលមានគោលដៅក្នុងការជំរុញការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។ សិក្ខាសាលានេះបានប្រព្រឹត្តទៅយ៉ាងរលូន និង ទទួលបានលទ្ធផលដូចការរំពឹងទុក ដោយមានអន្តរសកម្ម និង ការពិភាក្សាគ្នាយ៉ាងផុសផុលរវាងវាគ្មិន និង អ្នកចូលរួម ប្រកបដោយស្មារតីចែក-រំលែក និងយកចិត្តទុកដាក់ខ្ពស់។ តាមរយៈសិក្ខាសាលានេះ **គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល** ទទួលបាននូវធាតុចូលល្អៗជាច្រើនពីអ្នកចូលរួមដែលជាអ្នកជំនាញ និង មានបទពិសោធន៍ក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ដូចជាបានយល់ដឹងកាន់តែស៊ីជម្រៅពីឧត្តមានុវត្តន៍, ក្របខណ្ឌបទប្បញ្ញត្តិ, បញ្ហាប្រឈម និង ការវិវត្តចុងក្រោយនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ក៏ដូចជានៅបណ្តាប្រទេសដែលជាសមាជិកអាស៊ាន រួមមានប្រទេសសិង្ហបុរី, ថៃ, ឥណ្ឌូនេស៊ី និង ហ្វីលីពីន ផងដែរ។

សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនេះ គឺជាជំហានចាប់ផ្តើមដ៏ល្អនៅក្នុងដំណើរការនៃការតាក់តែងសេចក្តីព្រាងគោលនយោបាយដែលមានលក្ខណៈប្រទាក់ក្រឡា, មុតស្រួច, គ្រប់ជ្រុងជ្រោយ, និង ងាយបត់បែនប្រកបដោយប្រសិទ្ធភាព និង បរិយាបន្ន។ យ៉ាងណាមិញ, ការបន្តប្រមូលធាតុចូលល្អៗឱ្យបានកាន់តែច្រើន និងជាក់លាក់ពីតួអង្គពាក់ព័ន្ធក្នុងវិស័យសំខាន់ៗនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងដំណើរតាក់តែងសេចក្តីព្រាងគោល-នយោបាយនេះពិតជាមានភាពចាំបាច់។ ក្នុងន័យនេះ, **គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល** នឹងបន្តរៀបចំសិក្ខាសាលាជាបន្តបន្ទាប់ទៅតាមវិស័យនីមួយៗ ដូចជាវិស័យធានារ៉ាប់រង, វិស័យធនាគារ និង វិស័យហិរញ្ញវត្ថុវិមជ្ឈការ (Decentralized Finance)។

**គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល** មានជំនឿចិត្តយ៉ាងមុតមាំថា **គោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា** នឹងចូលរួមចំណែកក្នុងការកំណត់នូវទិសដៅ គោលការណ៍ និង វិធានការគោលនយោបាយ ក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា សម្រាប់ទាំងវិស័យហិរញ្ញវត្ថុធនាគារ, វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង វិស័យហិរញ្ញវត្ថុវិមជ្ឈការ ប្រកបដោយយុទ្ធសាស្ត្រ និង ភាពគ្រប់ជ្រុងជ្រោយ។ ការណ៍នេះនឹងអាចជួយកសាងមូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាពអាទិភាព និង ជាក់លាក់ សំដៅអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា។

KINGDOM OF CAMBODIA

Nation Religion King

Ministry of Economy and Finance

*Phnom Penh, April 27, 2022*

# Press Release

## National Consultation Workshop on Policy and Direction of Cambodia's Financial Technology

Digital technology is an integral part of people's daily life and provides opportunities for the creation of potential and innovative startups. The Royal Government of Cambodia has been paying close attention to maximizing the benefits of digital technology in building the digital economy, an important pillar of Cambodia's socio-economic development. In the context of COVID-19, digital technology has increasingly contributed to maintaining economic activities and stability, promoting economic diversification, and creating jobs as well as creating new potential businesses. In this regard, digitalization has become an influential trend and a driving force for Cambodia's economic growth.

In May 2021, the Royal Government of Cambodia launched the "**Cambodia Digital Economy and Society Policy Framework 2021-2035**", considering the digital economy as a new economic growth driver and an ecosystem that contributes to the increase of economic productivity in other sectors. Financial technology, commonly known as FinTech, is also an essential basis in the digital economy architecture. However, the FinTech sector in Cambodia has been facing several barriers including shortcomings and uncertainties in the regulatory frameworks, lack of digital enablers, lack of human resources, and lack of FinTech innovation in other sectors besides the banking sector.

To establish holistic policy measures for the FinTech development in Cambodia, the Digital Economy and Business Committee organized the National Consultation Workshop on "**Policy and Direction of Cambodia's Financial Technology**" for one day and a half on April 26 and 27, 2022 from 8:30 a.m. at Hyatt Regency Phnom Penh Hotel. This workshop was presided over by **His Excellency Akka Pundit Sopheacha Aun Pornmoniroth**, Deputy Prime Minister, Minister of Economy and Finance, and Chairman of the Digital Economy and Business Committee. The workshop was also attended by top officials and representatives from ministries and institutions, embassies, development partners, bank and non-bank institutions, associations, financial technology companies, businessmen, and innovators.

The National Consultation Workshop on **"Policy and Direction of Cambodia's Financial Technology"** was organized with three primary objectives: 1) to collect inputs from stakeholders for drafting Cambodia's FinTech development policy, 2) to enhance the

understanding of the current FinTech development and challenges in Cambodia, and 3) to exchange ideas and insights among professionals to foster the FinTech development in Cambodia. The workshop went smoothly and achieved the expected outputs, with interactive and lively discussions among presenters, panelists, and participants with a spirit of sharing and close attention. Through this workshop, **the Digital Economy and Business Committee** received valuable inputs from participants who are the experts with experience in the field of FinTech and gained a deeper understanding of the best practices in other countries from other ASEAN member countries including Singapore, Thailand, Indonesia, and the Philippines, and challenges and current development of FinTech in Cambodia.

This National Consultation Workshop is a good starting point in the process of drafting a connected, sharp, holistic, and agile policy with efficiency and inclusion. However, more insightful inputs from key stakeholders in specific sectors of FinTech are essential in the process of drafting this policy. In this regard, **the Digital Economy and Business Committee** will continue to organize a series of workshops in each specific sector such as insurance, banking, and decentralized finance.

**The Digital Economy and Business Committee** strongly believes that Cambodia's FinTech development policy will strategically and holistically contribute to setting the directions, principles, and policy measures for Cambodia's FinTech sector development as a whole including bank, non-bank, and decentralized finance. This will build a foundation to set priorities and specific action plans aimed at promoting digital economy development in Cambodia.